**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ៖ ៣៧៤២ "ឈ"

ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩

-សំណុំរឿងព្រហ្មទណ្ឌលេខ៖០៦៣

ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៨

-សំណុំរឿងស៊ើបសួរលេខ៖ ១២៧៤

ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៨

-សំណុំរឿងជំនុំជំរះលេខ៖ ១៤៨៤

ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩

**នាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង០២និង០០នាទី រសៀល នៅសាលសវនាការទី៤ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជំរះ**

លោក **ឯក ប៉ូលីហ្វើល** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក **ខាំ សុផារី** ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក **សុខ សេង** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ០៦៣ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទឈ្មោះ **សំប៊ុន យ៉ានី** ភេទស្រី អាយុ៦១ឆ្នាំ កើតឆ្នាំ១៩៥៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរនៅផ្ទះ កំរិតវប្បធម៌បាក់ឌុបពីសង្គមចាស់ ទីកន្លែងកំណើតសង្កាត់លេខ៥ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នផ្ទះលេខ១ ផ្លូវលេខ៨៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ សំប៊ុន គីមសួរ (ស្លាប់) ម្ដាយឈ្មោះ ឈន មុត (ស្លាប់) ប្ដីឈ្មោះ ង៉ោ ចាន់វ៉ាង (ស្លាប់) មានកូន ០៣នាក់ ជាទីតីជន ទោសពីមុនគ្មាន ។ **ក្រៅឃុំ** ។

ត្រូវជាប់ចោទពីបទ៖ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៩A ផ្លូវលេខ៥៦៤ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ។

-មានលោក **ស៊ី សគុន្ធា** អត្តលេខ៖ **៥២៤** ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ **សំប៊ុន យ៉ានី**

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ **ខួន សុរិយ៍** ភេទស្រី អាយុ៥៩ឆ្នាំ ជនជាតិខ្មែរ មុខរបរអតីតប្រធានស្ដីទីមណ្ឌលពត៌មានស្ត្រីកម្ពុជា ទីលំនៅបច្ចុប្បន្នផ្ទះលេខ២០៧ ផ្លូវលេខ១៥៦Z សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

-មានលោក **ឈះ ស៊ុនហុង** អត្តលេខ៖ **៧៣៣** និងលោក **នី ចាន់ឌី** អត្តលេខ៖ **៤១៤** ជាមេធាវីតំណាងអោយដើមបណ្ដឹង រដ្ឋប្បវេណីឈ្មោះ **ខួន សុរិយ៍** ។

**អង្គហេតុនៃរឿងមានដូចតទៅ**

ឈ្មោះ សំប៊ុន យ៉ានី ភេទស្រី កើតឆ្នាំ១៩៥៧ បានបំរើការនៅមណ្ឌលពត៌មានស្ត្រីកម្ពុជាតាំងពីអំឡុងឆ្នាំ២០០៣ ដោយមានតួនាទីចុងក្រោយជាប្រធានផ្នែកហិរញ្ញវត្ថុរហូតមកដល់ឆ្នាំ២០១៦ ទើបបានលាឈប់ ។ នៅក្នុងរយៈពេលបំពេញការងារ

ឱ្យចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទរូបនេះពីបទរំលោភលើទំនុកចិត្តតាមច្បាប់។ សេចក្តីសន្និដ្ឋានប្តឹងសុំនេះមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់អាចឱ្យតុលាការទទួលមកពិចារណា និងផ្តន្ទាទោសជនជាប់ចោទបាន ។

១០-សេចក្តីសន្និដ្ឋានការពាររបស់លោក ស៊ុំ សត្យា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ដែលបានសន្និដ្ឋានការពារថា៖ កូនក្តីរបស់ខ្លួនបាន សារភាពស្មោះត្រង់តាំងពីមុនពេលដើមបណ្តឹងប្តឹងមកតុលាការទៅទៀត ហើយគាត់ថែមទាំងបានធ្វើកិច្ចសន្យាសងប្រាក់ជំពាក់ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ហើយក្រោយមកគាត់ក៏បានសងប្រាក់ដល់ដើមបណ្តឹងបានចំនួន USD ៥០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក ហើយប្រាក់នៅសល់គាត់នៅតែសន្យាថានឹងសងជាបន្តទៀតរហូតគ្រប់ចំនួន ដោយគ្រាន់តែគាត់រង់ចាំប្រាក់ដែលបងប្អូនផ្ញើរមកពីបរទេសប៉ុណ្ណោះ នេះបញ្ជាក់ឱ្យឃើញថាកូនក្តីរបស់ខ្លួនមានភាពស្មោះត្រង់ បានសារភាពស្មោះត្រង់នូវអំពើដែលខ្លួនបានប្រព្រឹត្ត និងមានការទទួលខុសត្រូវចំពោះអំពើប្រព្រឹត្តរបស់ខ្លួន ។ ហេតុនេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ សំណូមពរសុំឱ្យតុលាការសម្រេចផ្តន្ទាទោសកូនក្តីខ្លួនដោយព្យួរទោស ព្រោះកូនក្តីខ្លួនមានវ័យចាស់មានជម្ងឺប្រចាំកាយ និងមានសុខភាពទ្រុឌទ្រោមខ្លាំង មិនអាចទ្រាំរស់នៅក្នុងមណ្ឌលឃុំខ្លួនបានឡើយ ។ សេចក្តីសន្និដ្ឋានប្តឹងសុំនេះមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់អាចឱ្យតុលាការទទួលមកពិចារណានិងសម្រេចបាន ។

១១-ជនជាប់ចោទឈ្មោះ សំប៊ុន យ៉ានី បាននិយាយសំដីចុងក្រោយថា៖ ខ្លួនសុំឱ្យតុលាការសម្រេចដោយមិនធ្វើការឃុំខ្លួនរូបខ្លួន ដើម្បីខ្លួនមានលទ្ធភាពរកប្រាក់សងដើមបណ្តឹងវិញ ។ គប្បីតុលាការលើកយកមកពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់ ។

១២-មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ សំប៊ុន យ៉ានី (មានអត្តសញ្ញាណខាងលើ) ពីបទ៖ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៩A ផ្លូវលេខ៥៦៤ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ។ គប្បីតុលាការពិចារណានិងសម្រេចសេចក្តីតាមច្បាប់ ។

១៣-ការទាមទារប្រាក់ចំនួន USD ២០៨.៩៧៩,៨២(ម្ភៃម៉ឺនប្រាំបីពាន់ ប្រាំបួនរយចិតសិបប្រាំបួនក្បៀសប៉ែតសិបពីរ)ដុល្លារអាមេរិក និងជម្ងឺចិត្តចំនួន USD ១៥.០០០(មួយម៉ឺន)ដុល្លារអាមេរិកដោយដើមបណ្តឹងរដ្ឋប្បវេណី ពីជនជាប់ចោទ គប្បីតុលាការពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់ លើការទាមទារប្រាក់ដែលដើមបណ្តឹងបាត់បង់ ដោយឡែកចំពោះការទាមទារការប្រាក់លើប្រាក់ដែលដើមបណ្តឹងបាត់បង់ តុលាការមិនគប្បីលើកយកមកពិចារណា និងសម្រេចឡើយ។

## <u>ហេតុដូច្នេះសម្រេច</u>

១-ផ្តន្ទាទោសឈ្មោះ **សំប៊ុន យ៉ានី** ភេទស្រី កើតឆ្នាំ១៩៥៧ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (**មួយ**)**ឆ្នាំ** ប៉ុន្តែទោសនេះត្រូវព្យួរធម្មតាទាំងស្រុង ពីបទ៖ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៩A ផ្លូវលេខ ៥៦៤ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា៣៩១ មាត្រា៣៩២ និងមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ ។

២-ឱ្យឈ្មោះ **សំប៊ុន យ៉ានី** សងប្រាក់ចំនួនUSD២០៨.៩៧៩,៨២(ម្ភៃម៉ឺនប្រាំបីពាន់ប្រាំបួនរយចិតសិបប្រាំបួនក្បៀសប៉ែតសិបពីរ)ដុល្លារអាមេរិក ទៅអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ វួន សុរិយ៉ា ឯការទាមទារលើសពីនេះលើកចោល ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ សំប៊ុន យ៉ានី មេធាវី ស៊ុ សត្យា និងមេធាវីការពារក្តីនិងជាតំណាងឲ្យដើមបណ្តឹងលោក ទី ចាន់ឌី និងប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

-គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា **សុខ សេខ**

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា **ឯក ប៉ូលីហ្វីល**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ០៧កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩

ឃើញ
ចៅក្រម

**ឯក ប៉ូលីហ្វីល**

ក្រឡាបញ្ជី

សុខ សេខ